កំណាព្យ

# ផ្ទះខ្មែរ

(បទកាកគតិ)



និពន្ធដោយលោក វ៉ែន សុន
វិចិត្ររូបភាពដោយ លោក គាំ សាវ៉ែន
បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្ត

នេះនឹងចារចែង ពាក្យកាព្យថ្លាថ្លែង អំពីផ្ទះខ្មែរ

មានច្រើនសណ្ឋាន បុរាណបានថែ សម័យផងដែរ

ហូរហែប្លែកគ្នា ។



ខ្ទមស្លឹកទាបខ្ពស់
នៅចំការស្រែ

គ្រួសាររួមរស់
ពុកម៉ែមីងមា
ភោគផលដំណាំ ។

ការក្ដៅរងា
ស្នាក់នៅការពារ



រោងខ្ពស់វែងខ្លី រោងខ្លះផ្ទាល់ដី រោងថ្មីចូលឆ្នាំ
រោងការរោងបុណ្យ ល្ខោនកុនឆៃយ៉ាំ រោងរាំរបាំ
ហៅរោងសិល្បៈ ។



ផ្ទះស្លឹកផ្ទះឈើ បុរាណលោកធ្វើ សំរាប់ទីស្នាក់
រោងដោលដំបូល ខ្យល់ចូលឥតអាក់ ហោជាងមួយដាក់
បានសុខសួស្តី ។



រីផ្ទះរោងខឿង ប្រក់ស្លឹកប្រក់ក្បឿង កើនសុខសិរី
ហោជាងមុខក្រោយ បណ្តោយវែងខ្លី សង់ខ្ពស់ពីដី
តាមទម្លាប់ខ្មែរ ។



កន្តាំងមួយខ្នង មានរានហាលផង បង្កាន់ដៃដែរ
អង្គុយផ្អែកប្រាណ សន្តាននៅក្បែរ ជុំគ្នាហូបតែ
សំរាកកិច្ចការ ។



កន្តាំងស្លាបថ្មី ខ្ពងពីរខ្ពងបី សមតាមតម្រា

ខ្លះមានហោណាំង ខ្លះតាំងបង្ហា ទម្លាប់ដូនតា

បួនល្វែងដូចគ្នា ។



ផ្ទះប៉ិតយើងខ្មែរ នៅចំការស្រែ ទីក្រុងនានា
ប្រក់ស្លឹកប្រក់ក្បឿង ក្បាច់គ្រឿងធានា គង់នៅយូរយារ
កេរពីបុរាណ ។



ម៉ូតផ្ទះប្លែកៗ បុរាណច្នៃចែក ល្អឯកចំណាន

ដូចមាត់ក្រពើ មានពីបុរាណ ច្រើនបង្អួតប្រាណ

នៅតាមទីផ្សារ ។



ផ្ទះប៉ិតហោណាំង មានដូចកន្តាំង ខ្លះមានបង្ហា
តាមតែម្ចាស់ផ្ទះ ឱ្យជាងរចនា ក្រុងស្រែចំការ
ទៅតាមធនធាន ។



ឯផ្ទះបែបថ្មី ដំបូលយ៉ាបខ្លី ផ្ទាល់ដីក៏មាន

សង់បែបបង្ហា ផ្ទះផ្សាររោងរៀន ដំបូលព្រំគ្មាន

តាមម៉ូតតម្រូវ ។



ផ្ទះច្រើនទៀតដែរ មួយឈ្មោះផ្ទះខ្មែរ សាងសង់ស្ថិតស្ថាង
ជញ្ជាំងសមរាង ហោជាងសងខាង ក្បាលនាគច្រូងច្រាង
ជហ្វាជងក្តារ ។



ផ្ទះថ្មផ្ទះឈើ ព្រះពន្លាធ្វើ សំរាប់ក្សត្រា

ប្រថាប់ក្រសាល សំរាលកាយា ដេញខ្មាំងឫស្យា

ហៅពន្លាជ័យ ។



វាំងប្រាសាទ កំពូលស្អាងស្អាត រចនាប្រពៃ
ហៅរាជដំណាក់ ទ្រង់ស្នាក់គ្មានភ័យ គ្រប់ផ្ទះមានន័យ
ជាព្រលឹងខ្មែរ ។



ផ្ទះខ្មែរច្រើនម្លឹង មានឈ្មោះផ្ទះកឹង ដូចប្រាសាទដែរ

គឺព្រះវិហារ នៅនាក្រុងស្រែ ជូនតាបានថែ

គង់នៅសព្វថ្ងៃ ។



ផ្ទះខ្មែរច្រើនណាស់ បែបថ្មីបែបចាស់ សង់ច្រើនក្រាស់ក្រៃ

ដំណែលជូនតា រក្សាសព្វថ្ងៃ បុរាណកែច្នៃ

ទុកតកូនចៅ ។/

*** ចប់ ***

